អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ការចូលរួមរបស់សាធារណជន និងប្រព័ន្ធផ្សព្វផ្សាយក្នុងសវនាការស្តីពី បញ្ហាកាយសម្បទាជនជាប់ចោទក្នុងសំណុំរឿង ០០២ ដែលប្រព្រឹត្តទៅពីថ្ងៃទី២៩ ដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១១

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានកំណត់កាលបរិច្ឆេទនៃសវនាការស្តីអំពីបញ្ហាកាយសម្បទាក្នុងការចូលរួមសវនាការទាក់ទងនឹងជនជាប់ចោទអៀង ធីរិទ្ធ និង នួន ជា ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០១១។ សវនាការនឹងចាប់ផ្តើមឡើងនៅថ្ងៃចន្ទ ទី២៩ ខែសីហា វេលាម៉ោង ៩ ព្រឹក។

សវនាការនេះត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឲ្យមានការសួរសំណួរដល់អ្នកជំនាញដែលត្រូវបានចាត់តាំងឡើងគឺលោកសាស្ត្រាចារ្យ ចន ខាំបែល និងការអំណះអំណាងជំទាស់ផ្សេងៗដែលលើកឡើងដោយមេធាវីការពារក្តីអៀង ធីរិទ្ធ និងនួន ជា សហព្រះរាជអាជ្ញា និងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅលើសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់លោកសាស្ត្រាចារ្យ ខាំបែល ទាក់ទងនឹងជនជាប់ចោទ នួន ជា និងអៀង ធីរិទ្ធ។ លោកសាស្ត្រាចារ្យ ខាំបែល ត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទទាំងអស់ ដែលតវ៉ាអំពីកាយសម្បទារបស់ខ្លួនក្នុងការចូលរួមសវនាការ ឬលទ្ធភាពអង្គុយក្នុងសវនាការរយៈពេលយូរ។ -

អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា អនុលោមតាមវិធាន ៧៩(៦) សវនាការទាំងនេះនឹងត្រូវធ្វើឡើងជាសាធារណៈឲ្យបានច្រើនតាមតែអាចធ្វើទៅបាន។ ប៉ុន្តែ អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់អំពីភាពចាំបាច់ ដែលត្រូវថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការការពារនូវភាពសម្ងាត់ឯកជនរបស់ខ្លួនអំពីព័ត៌មានខាង

ផ្នែកវេជ្ជសាស្ត្រ ជាមួយនឹងសិទ្ធិរបស់សាធារណជនក្នុងការដឹងអំពីព័ត៌មានទាំងនេះ នៅពេលដែលការសម្រេចលើពាក្យសុំពាក់ព័ន្ធនឹងសម្បទាក្នុងការចូលរួមសវនាការកំពុងស្ថិតនៅក្នុងការពិចារណានៅឡើយ។ សវនាការទាំងអស់នឹងប្រព្រឹត្តទៅជាសាធារណៈ។ ចំណុចណាមួយដែលភាគីយល់ថា សវនាការគួរធ្វើជាសម្ងាត់ ភាគីត្រូវស្នើសុំអង្គជំនុំជម្រះដោយផ្ទាល់មាត់។ សំណើទាំងនេះនឹងត្រូវស្ដាប់ក្នុងសវនាការជាសាធារណៈ ហើយអង្គជំនុំជម្រះនឹងឯកភាព ប្រសិនបើអង្គជំនុំជម្រះយល់ថា ផលប្រយោជន៍យុត្តិធម៌តម្រូវដូច្នេះ។

**ព័ត៌មានសម្រាប់សាធារណជន**

នៅក្នុងសាលសវនាការរបស់ អ.វ.ត.ក.មានកៅអីចំនួន ៤៨២។ កៅអីចំនួន ១៤០ ត្រូវបានរក្សាទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ មន្ត្រីការទូត និងតំណាងប្រព័ន្ធផ្សព្វផ្សាយ។ ចំណែកកៅអីដែលនៅសល់នឹងត្រូវផ្ដល់ជូនដល់សាធារណជនទូទៅតាមគោលការណ៍មកមុនបានមុននៅថ្ងៃសវនាការ។ អង្គការក្រៅរដ្ឋាភិបាល សាលារៀន និងស្ថាប័នផ្សេងៗទៀតដែលមានបំណងនាំក្រុមសាធារណជនមកចូលរួមក្នុងសវនាការ ត្រូវចុះឈ្មោះជាមុនជាមួយនឹងផ្នែកកិច្ចការសាធារណៈរបស់ អ.វ.ត.ក. ដោយទាក់ទងតាមរយៈ pas@eccc.gov.kh។

មន្ត្រីការទូតដែលមានបំណងក្នុងការកក់កន្លែងអង្គុយ សូមអញ្ជើញចុះឈ្មោះតាមរយៈ pas@eccc.gov.kh។

អ.វ.ត.ក សូមស្នើដល់សាធារណជនអញ្ជើញមកដល់កន្លែងត្រួតពិនិត្យសន្តិសុខចន្លោះពីម៉ោង ៧ និង ៣០នាទី ដល់ម៉ោង ៨ព្រឹកដើម្បីមានពេលគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យសន្តិសុខ និងជូនប័ណ្ណចូលសវនាការ។ ទ្វារសាលសវនាការនឹងត្រូវបិទនៅម៉ោង ៨ និង ៤៥ នាទីព្រឹក ឬក៏នៅពេលដែលកន្លែងអង្គុយក្នុងសាលសវនាការត្រូវបានអង្គុយពេញអស់។

ដើម្បីចូលក្នុងបរិវេណសាលសវនាការ សាធារណជនគ្រប់រូបត្រូវតែបង្ហាញអត្តសញ្ញាណប័ណ្ណដែលមានបិទរូបថត និងឆ្លងកាត់ការត្រួតពិនិត្យសន្តិសុខ។ សូមកត់សម្គាល់ថា អ្នកដែលមានអាយុក្រោម ១៦ ឆ្នាំ នឹងមិនត្រូវអនុញ្ញាតឱ្យចូលក្នុងសាលសវនាការឡើយ ហើយអ្នកដែលមានអាយុចន្លោះពី១៦ ដល់ ១៨ ឆ្នាំអាចចូលបានលុះត្រាតែមានមនុស្សចាស់មកជាមួយ។ សាធារណជនត្រូវតែមានអាកប្បកិរិយាថ្លៃថ្នូរ និងសមរម្យគ្រប់ពេលវេលា និងមានសម្លៀកបំពាក់សមរម្យ។ មិនអនុញ្ញាតឱ្យយកទូរស័ព្ទដៃ ម៉ាស៊ីនថតរូប កុំព្យូទ័រយួរដៃ ឧបករណ៍ថតសំឡេង កាបូបធំៗ អាហារ ឬក៏ភេសជ្ជៈចូលក្នុងសាលសវនាការឡើយ។

អ.វ.ត.ក មានទីតាំងនៅសង្កាត់ចោមចៅ ចម្ងាយ ១៦ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ខាងឆ្វេងផ្លូវជាតិលេខ ៤។ សាធារណជន និងតំណាងសារព័ត៌មានសូមអញ្ជើញចូលតាមច្រកសម្រាប់ភ្ញៀវ ដែលស្ថិតនៅផ្នែកខាងកើតនៃបរិវេណ អ.វ.ត.ក។ អ.វ.ត.ក មានទីធ្លាសម្រាប់ឱ្យភ្ញៀវចតយានយន្ត។

**ប័ណ្ណព័ត៌មានសម្រាប់តំណាងប្រព័ន្ធផ្សព្វផ្សាយ**

ការចុះឈ្មោះជាមុន និងប័ណ្ណព័ត៌មានជាតម្រូវការចាំបាច់សម្រាប់តំណាងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ដើម្បីអាចចូលរួមនៅក្នុងបរិវេណ អ.វ.ត.ក នៅថ្ងៃទី២៩ ដល់ ៣១ ខែសីហា ឆ្នាំ ២០១១។ នីតិវិធីខាងក្រោមនេះគឺដើម្បីឆ្លើយ

តបទៅនឹងតំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានបំណងចូលយកក្នុងបរិវេណ អ.វ.ត.ក:

ក-ចំពោះអ្នកដែលមានប័ណ្ណព័ត៌មានអ.វ.ត.ក ដែលមានសុពលភាពនៅឡើយ ត្រូវចុះឈ្មោះចូលរួមក្នុងសវនាការបឋមនេះជាមួយនឹងផ្នែកកិច្ចការសាធារណៈ ដោយផ្ញើអ៊ីមែលតាមរយៈ pas@eccc.gov.kh។

ខ-ចំពោះអ្នកដែលកាន់ប័ណ្ណព័ត៌មានដែលហួសសុពលភាព ត្រូវដាក់ជាថ្មីនូវទម្រង់បែបបទសុំប័ណ្ណព័ត៌មានដោយបំពេញតាមបែបបទ និងចុះហត្ថលេខាផងដែរ ជាមួយការស្នើសុំចុះឈ្មោះចូលរួមទៅកាន់អាសយដ្ឋានអេឡិចត្រូនិក pas@eccc.gov.kh។ សូមមេត្តាបញ្ជាក់លេខប័ណ្ណនៅលើប័ណ្ណព័ត៌មានរបស់អ.វ.ត.កដែលហួសសុពលភាព។

គ-ចំពោះអ្នកដែលមិនមានប័ណ្ណព័ត៌មានរបស់អ.វ.ត.ក ត្រូវបំពេញសំណុំបែបបទ និងចុះហត្ថលេខាលើទម្រង់បែបបទនៃការស្នើសុំប័ណ្ណព័ត៌មាន ដោយភ្ជាប់មកជាមួយនូវរូបថតបិទកាតក្នុងទម្រង់ jpg ស្កែនអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរួមជាមួយនឹងការស្នើសុំចុះឈ្មោះ រួចផ្ញើទៅកាន់ pas@eccc.gov.kh។

ទម្រង់សម្រាប់ស្នើសុំប័ណ្ណព័ត៌មានអាចទាញចេញពីគេហទំព័ររបស់ អ.វ.ត.ក
http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Application_Form.doc.

កន្លែងអង្គុយចំនួន ៣០នឹងត្រូវរៀបចំសម្រាប់តំណាងសារព័ត៌មាន ហើយអាទិភាពគឺសម្រាប់សារព័ត៌មានបោះពុម្ព។ តំណាងសារព័ត៌មានដទៃទៀតអាចអង្គុយនៅក្នុងបន្ទប់ព័ត៌មាន ដែលមានទីតាំងនៅជាន់ផ្ទាល់ដីនៃសាលសវនាការ។ តំណាងសារព័ត៌មានដែលមានបំណងចូលទៅអង្គុយនៅក្នុងសាលសវនាការ សូមមេត្តាចុះឈ្មោះដើម្បីរក្សាកន្លែងទុកជាមួយនឹងការចុះឈ្មោះចូលរួមទស្សនាសវនាការ។ កាលបរិច្ឆេទផុតកំណត់សម្រាប់ការចុះឈ្មោះ និងការស្នើសុំប័ណ្ណព័ត៌មាននឹងផុតកំណត់នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១១។

*កំណត់សម្គាល់: អវតកនឹងផ្តល់សេវាដឹកជញ្ជូនដោយឥតគិតថ្លៃសម្រាប់តំណាងសារព័ត៌មានទាំងឡាយសម្រាប់ការធ្វើដំណើរមកកាន់សាលាក្តីខ្មែរក្រហម និងវិលត្រឡប់ទៅវិញ។ ជួបជុំគ្នានៅការិយាល័យ អ.វ.ត.ក.នៅរាជធានីភ្នំពេញនៅផ្ទះលេខ ៦A ផ្លូវ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្បែរផ្សារកាប់គោ។ ព័ត៌មានលម្អិតសូមទាក់ទងលោក នេត្រ ភក្ត្រា មន្ត្រីនាំពាក្យអ.វ.ត.ក.។*

**ការផ្តល់ជូនអ្នកសារព័ត៌មាន**

ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក នឹងផ្តល់មធ្យោបាយនានា នៅជាន់ផ្ទាល់ដីនៃអគារសវនាការ ដើម្បីជួយសម្រួលដល់អ្នកសារព័ត៌មានក្នុងអំឡុងពេលសវនាការ។ យើងមានទូដាក់ឥវ៉ាន់សម្រាប់អ្នកសារព័ត៌មានរក្សាទុកសម្ភារផ្ទាល់ខ្លួនមួយចំនួនដូចជា ទូរស័ព្ទដៃ ម៉ាស៊ីនថត ឬកាបូបធំៗជាដើម។

នៅក្នុងបន្ទប់ការងារព័ត៌មាន (លេខ C១០៨) នៅជាន់ផ្ទាល់ដីនៃអគារសវនាការ មានទីកន្លែងស្ងប់ស្ងាត់សម្រាប់ធ្វើការ និងមានកុំព្យូទ័រមួយចំនួនដែលភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតរួចជាស្រេច សម្រាប់អ្នកសារព័ត៌មានប្រើប្រាស់តាមគោលការណ៍មកមុនបានមុន។ អ្នកសារព័ត៌មានអាចយកកុំព្យូទ័រយួរដៃផ្ទាល់ខ្លួនមកប្រើប្រាស់នៅទីនេះបាន

ក៏ប៉ុន្តែពុំអនុញ្ញាតឲ្យភ្ជាប់ទៅនឹងបណ្តាញអ៊ីនធឺណិត ឬបណ្តាញកុំព្យូទ័ររបស់ អ.វ.ត.ក ឡើយ។ សូមបញ្ជាក់ថា អ.វ.ត.ក ពុំមានផ្តល់ប្រព័ន្ធអ៊ីនធឺណិតគ្មានខ្សែឡើយ ដូច្នេះបើអ្នកសារព័ត៌មានណាម្នាក់ មានបំណងភ្ជាប់អ៊ីនធឺណិតទៅនឹងកុំព្យូទ័រផ្ទាល់ខ្លួន សូមយកឧបករណ៍ 3G modems ផ្ទាល់ខ្លួនមកជាមួយ។

អ.វ.ត.ក នឹងមានការផ្តល់ការផ្សាយបន្តផ្ទាល់ជាវីដេអូ និងសំឡេង អំពីដំណើរការសវនាការ នៅក្នុងបន្ទប់សម្រាប់អ្នកសារព័ត៌មាន (C-១០៥) ដែលស្ថិតនៅជាន់ផ្ទាល់ដីនៃសាលសវនាការ។ ការផ្សាយបន្តផ្ទាល់តាមរយៈទូរទស្សន៍ជាភាសាខ្មែរ នៅក្នុងបន្ទប់ C១០៩ និងភាសាអង់គ្លេសនៅក្នុងបន្ទប់ C១០៥ សម្រាប់តែអ្នកសារព័ត៌មានប៉ុណ្ណោះ។

**កៅអីដែលត្រៀមបម្រុងសម្រាប់អ្នកសារព័ត៌មានក្នុងសាលសវនាការ**

អ្នកសារព័ត៌មានត្រូវតែមកដល់កន្លែងអង្គុយរបស់ខ្លួនឲ្យបាន៣០នាទីមុនពេលបើកសវនាការ។ ពុំអនុញ្ញាតឲ្យយកម៉ាស៊ីនថតរូប កុំព្យូទ័រយួរដៃ ទូរស័ព្ទដៃ ឬឧបករណ៍ថតសំឡេង ចូលក្នុងសាលសវនាការឡើយ។

**ការថតរូបភាព**

ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក នឹងផ្តល់រូបភាពជូនអ្នកសារព័ត៌មាននៅពេលចាប់ផ្តើមសវនាការ។

**ការថតសំឡេង**

ឧបករណ៍សម្រាប់ថតសំឡេងនៃដំណើរការសវនាការ នឹងត្រូវបានផ្តល់ជូនអ្នកសារព័ត៌មានតាមប្រព័ន្ធ **PHONO/XLR**។ ឧបករណ៍ថតសំឡេងនេះ អាចប្រើប្រាស់បាននៅក្នុងបន្ទប់តាមដានព័ត៌មាន (លេខ ១០៥) ដោយប្រើឧបករណ៍ភ្ជាប់មួយក្នុងចំណោមឧបករណ៍ភ្ជាប់ចំនួន ៤៨ (មានឧបករណ៍ភ្ជាប់ចំនួន១៦ សម្រាប់ភាសានីមួយៗ ខ្មែរ អង់គ្លេស និងបារាំង)។ ឧបករណ៍ភ្ជាប់បន្ថែមលើសពីនេះសម្រាប់ភ្ជាប់ពីម៉ាស៊ីនថតសំឡេងមួយ ទៅម៉ាស៊ីនថតសំឡេងមួយទៀត អាចធ្វើទៅបាន ប្រសិនបើអ្នកសារព័ត៌មាន បានយកខ្សែកាបសម្រាប់ភ្ជាប់មកជាមួយ។ សូមបញ្ជាក់ថា ពុំអនុញ្ញាតឲ្យថតសំឡេងនៅក្នុងបន្ទប់សវនាការឡើយ។

**ការថតវីដេអូ**

ឧបករណ៍សម្រាប់ថតចម្លងវីដេអូពីដំណើរការសវនាការនឹងត្រូវបានផ្តល់ជូនតាមប្រព័ន្ធBNC (PAL signal) ។ ការថតចម្លងវីដេអូ អាចធ្វើទៅបាននៅក្នុងបន្ទប់តាមដានព័ត៌មាន(បន្ទប់លេខ ១០៥) ដោយភ្ជាប់ឧបករណ៍មួយក្នុងចំណោមឧបករណ៍សម្រាប់ភ្ជាប់ចំនួន៣០ ដែលមាននៅទីនោះ។ ការថតចម្លងដោយប្រើខ្សែកាបបន្ថែម ពីម៉ាស៊ីនថតចម្លងមួយទៅម៉ាស៊ីនថតចម្លងមួយទៀតអាចធ្វើទៅបាន ប្រសិនបើអ្នកសារព័ត៌មាន បានយកខ្សែកាបមកជាមួយ។ សូមបញ្ជាក់ថា ពុំអនុញ្ញាតឲ្យថតវីដេអូនៅក្នុងបន្ទប់សវនាការឡើយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥ (០)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh